Khmer

# fact sheet

# ស្ត្រីនិងមេរោគ *HIV*
# ការធ្វើតេស្ត

(Women and HIV - Fact Sheet No 1 - Testing)

1

March 1997
[NGO-6070]

មូលហេតុដែលបណ្ដាលឲ្យអ្នកត្រូវសំរេចចិត្តថា គួរត្រូវធ្វើតេស្តដើម្បីរកមេរោគ **HIV** មានដូចតទៅ:

- បើអ្នកមានការសង្ស័យថា ឬបានដឹងថាខ្លួនអ្នកមានទទួលចំលងមេរោគនេះ បន្ទាប់ពីពេលអ្នកបានរួមភេទដោយគ្មានប្រដាប់ការពារតាមយោនីឬតាមរន្ធគូថ ជាមួយជនណាម្នាក់ និង/ឬបើអ្នកប្រើប្រដាប់ចាក់គ្រឿងញៀនចូលគ្នានឹងមនុស្សម្នាក់ទៀត។
- បើអ្នកបានដឹងប្រាកដឬសង្ស័យថា គូរស្រករអ្នកបានរួមភេទដោយគ្មានប្រដាប់ការពារជាមួយជនណាម្នាក់ទៀត។
- បើអ្នកចាប់ផ្ដើមមានគូរស្រករថ្មី ហើយចង់ធ្វើតេស្តសំរាប់ខ្លួននិងគូរស្រករអ្នក។
- បើអ្នកមានផ្ទៃពោះឬគិតចង់បានកូន។

ចាប់តាំងពីឆ្នាំ 1985 មក ឈាមដែលជាអំណោយក្នុងប្រទេសអូស្ត្រាលីទាំងមូលត្រូវបានគេពិនិត្យរកមើលមេរោគ HIV ទាំងអស់។ មុនពេលនេះ ជនដែលមានជម្ងឺហេម៉ូហ្វីលលា (haemophelia) និងជនដទៃទៀតដែលទទួលការបញ្ចូលឈាម តែងមានគ្រោះថ្នាក់ឆ្លងរោគ។

មានមូលហេតុល្អៗជាច្រើនដែលបណ្ដាលឲ្យអ្នកចង់ធ្វើតេស្តរកមេរោគ HIV ។

ក) វាអាចផ្ដល់ឱកាសឲ្យអ្នកដឹងថា អំពើដែលអ្នកបានប្រព្រឹត្តកន្លងមកហើយនោះ បណ្ដាលឲ្យអ្នកមានគ្រោះថ្នាក់ឬទេ? ឧទាហរណ៍: ការរួមភេទឬការចាក់គ្រឿងញៀនជាដើម។

ខ) ការរកឃើញមេរោគ HIV បានទាន់ពេល អាចឲ្យអ្នកមានជំរើសជាច្រើនក្នុងការព្យាបាល។ ការព្យាបាលតាមរបៀបសម័យដោយថ្នាំច្រើនផ្សំគ្នា អាចមានប្រសិទ្ធភាពទប់ទល់នឹងមេរោគ HIV ក្នុងខ្លួនអ្នក។ បើព្យាបាលទាន់ពេល ជាការប្រសើរ។

គ) វាអាចផ្ដល់ឱកាសប្រសើរក្នុងការថែទាំខ្លួនអ្នក និងត្រួតពិនិត្យសុខភាពព្រមទាំងរក្សាគុណភាពជីវិតអ្នកផង។

ហេតុដូច្នេះ បើអ្នកគិតថាខ្លួនអ្នកអាចមានប៉ះពាល់មេរោគ HIV ការធ្វើតេស្តគឺជាការប្រសើរបំផុត។

## ការផ្ដល់ឱវាទ • ការយល់ព្រម • ភាពសម្ងាត់

មានគោលការណ៍ជាមូលដ្ឋាន 3 សម្រាប់ចងចាំនៅគ្រាធ្វើតេស្ត:

1. *ការផ្ដល់ឱវាទ* – នៅពេលទទួលឱវាទមុនពេលធ្វើតេស្ត គេនឹងប្រាប់អ្នកអំពីការធ្វើតេស្តនោះ គេនឹងពិភាក្សាពន្យល់ថា តើការធ្វើតេស្តមានន័យយ៉ាងណា ហើយយ៉ាងដូចម្ដេចបានជាអ្នកធ្វើតេស្តនោះ។ គោលបំណងនៃការផ្ដល់ឱវាទមុនពេលធ្វើតេស្ត គឺកុំឲ្យអ្នកយល់ច្រឡំថា អ្នកត្រូវតែធ្វើតេស្តនោះ ក៏ប៉ុន្តែជាឱកាសសំរាប់ឲ្យអ្នកសំរេចថា តើគួរធ្វើតេស្តឬទេ។ អ្នកត្រូវតែមានចិត្តស្មោះត្រង់ចំពោះរូបអ្នក អំពីការប្រព្រឹត្តិរបស់អ្នក និងការដែលអ្នកដទៃប្រព្រឹត្តមកលើអ្នក និងអំពីស្ថានភាពដែលអាចបណ្ដាលឲ្យអ្នកមានគ្រោះថ្នាក់។ ការប៉ាន់ប្រមាណនេះត្រូវធ្វើរួមគ្នារវាងអ្នក និងវេជ្ជបណ្ឌិតអ្នក ឬគិលានុបដ្ឋាក ឬអ្នកផ្ដល់ឱវាទ។ អ្នកអាចសួរសំណួរតាមចិត្ត ហើយត្រូវសុំប័ណ្ណពត៌មានស្ដីអំពីមេរោគ HIV យកទៅអានបន្ថែមទៀត ដើម្បីធ្វើការសំរេចចិត្តថា អ្នកត្រូវធ្វើតេស្តនោះឬទេ។

បើអ្នកបានធ្វើតេស្ត HIV រួចហើយ អ្នកត្រូវត្រឡប់ទៅជួបគិលានុបដ្ឋាកឬវេជ្ជបណ្ឌិតនោះវិញ ដើម្បីទទួលលទ្ធផលដោយផ្ទាល់ខ្លួន។ គេនឹងមិនផ្ដល់ពត៌មានតាមទូរស័ព្ទទេ។ នៅពេលទៅទទួលលទ្ធផលនៃការធ្វើតេស្ត អ្នកគួរបានទទួលឱវាទក្រោយការធ្វើតេស្តមួយទៀត។ ការផ្ដល់ឱវាទលើកនេះមានរួមបញ្ចូលទាំងការគាំទ្រនិងពត៌មានសំខាន់ៗ (ឈ្មោះអង្គការដែលផ្ដល់ការគាំទ្រនិងពត៌មាន) ក៏ដូចជាឱកាសមួយអាចផ្ដល់ឲ្យអ្នកអាចកែប្រែចរិយាមាយាទឲ្យផុតគ្រោះថ្នាក់។ ទោះបីជាលទ្ធផលនៃការធ្វើតេស្តនោះយ៉ាងណាក៏ដោយ ការទទួលឱវាទក្រោយពីការធ្វើតេស្តគឺជាការចាំបាច់។

**គេមិនអាចធ្វើតេស្ត HIV**
**ដោយគ្មានការដឹងឮ នឹងគ្មាន**
**ការយល់ព្រមទាំងស្រុងពីអ្នកឡើយ។**

2. *ការយល់ព្រម* – ការយល់ព្រមមានន័យថា អ្នកបានយល់ ច្បាស់ថាការធ្វើតេស្តនោះមានអ្វីខ្លះ ផលវិបាកបន្ទាប់ពីបានដឹងថា អ្នកមានមេរោគ HIV និងសេរីភាពរបស់អ្នកក្នុងការសំរេចចិត្ត។

តាមច្បាប់ វេជ្ជបណ្ឌិតឬគិលានុបដ្ឋាកត្រូវតែប្រាប់អ្នកឲ្យបានក្បោះក្បាយអំពីរឿងធ្វើតេស្ត និងបានទទួលការយល់ព្រមធ្វើតេស្តនោះ (ឬទម្រង់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ ការព្យាបាលឬតេស្តដទៃទៀត) ពីអ្នក។ មានបញ្ហាសំខាន់ៗផ្សេងទៀតដែល អ្នកត្រូវគិតមើល បើអ្នកសំរេចចិត្តថា ព្រមធ្វើតេស្តនោះ ឧទាហរណ៍: តើលទ្ធផលនៃការធ្វើតេស្តនោះមានឥទ្ធិពលយ៉ាងណាទៅលើរូបអ្នក? អ្នកអាចចង់បានការគាំទ្រនិងជនម្នាក់ទៀត សម្រាប់ពិគ្រោះពីរឿងធ្វើតេស្តនេះ ដូចជាក្រុមគ្រួសារ មិត្តភក្តិ ឬអ្នកមានវិជ្ជាជីវៈខាងការថែទាំសុខភាព (វេជ្ជបណ្ឌិត គិលានុបដ្ឋាក សង្គមការី)។

3. *ភាពសម្ងាត់* – គ្រប់ដំណាក់ការនៃការធ្វើតេស្តនេះ ស្ថិតនៅក្នុងភាពសំងាត់ទាំងអស់ គឺចាប់តាំងពីពេលដែលអ្នកសំរេចចិត្តថាត្រូវធ្វើតេស្ត រហូតដល់ពេលទទួលលទ្ធផល។ ជាការពិតណាស់ រូបអ្នកផ្ទាល់អាចនិយាយប្រាប់អ្នកណាទៀតបានដោយសេរី ក៏ប៉ុន្តែបុគ្គលិកសុខាភិបាលមិនអាចផ្ដល់ពត៌មានទៅជនណាម្នាក់ទៀតដោយគ្មានការអនុញ្ញាតពីរូបអ្នកឡើយ។ ចូរអ្នកពិគ្រោះរឿងនេះជាមួយបុគ្គលិកសុខាភិបាល បើអ្នកនៅមានការសង្ស័យ។

នៅក្នុងមន្ទីរពេទ្យវិញ មានតែបុគ្គលិកសុខាភិបាល វេជ្ជបណ្ឌិត និងអ្នកផ្ដល់ឱវាទដែលថែទាំអ្នកទេ ដែលមានសិទ្ធិដឹងឮថា អ្នកមានមេរោគ HIV ។

**fact sheet 1of 6**

**A series of fact sheets for women about HIV**

**1 Testing**
**2 Newly Diagnosed**
**3 Symptoms**
**4 Treatments**
**5 Preganancy**
**6 Parenting**

សេរីនៃក្រដាសពត៌មានសម្រាប់ស្ត្រី អំពីមេរោគ HIV ។

ការធ្វើតេស្ត
ទើបតែរកឃើញថា មានមេរោគ
រោគសញ្ញា
ការព្យាបាល
ផ្ទៃពោះ
ការធ្វើជាមាតាបិតា

***Produced by* FPA Health *and* Multicultural HIV/AIDS Service based on material written by FPA Health & AIDS Council of NSW**

**Available from FPA Health**
**Ph: 9716 6099**
**Fax: 9716 6164**
***and***
**MHAS**
**Ph: 9515 3098**
**Fax: 9550 6815**

FPA health

**Funded by NSW Department for Women**

## តើការធ្វើតេស្តជាអ្វីទៅ?

នៅពេលមានការឆ្លងរោគឬវីរុស ខ្លួនអ្នកតែងបង្កបង្កើតអង្គបដិបក្ខ (antibodies)។ បើអ្នកបានឆ្លងមេរោគ HIV នោះអង្គបដិបក្ខ HIV នឹងកើតមានឡើងនៅក្នុងឈាមរបស់អ្នក។ ការធ្វើតេស្តមេរោគ HIV គឺជាការស្វែងរកថា តើមានសញ្ញាអង្គបដិបក្ខ HIV ដែរឬទេ។

បើអ្នកសំរេចចិត្តថានឹងធ្វើតេស្តនោះ វេជ្ជបណ្ឌិតឬគិលានុបដ្ឋាកនឹងយកឈាមមួយចំនួន ដោយបិទផ្លាកសរសេរអក្សរកាត់ពីរតួជាតំណាងនាមត្រកូលនិងនាមខ្លួនរបស់អ្នក ថ្ងៃខែឆ្នាំកំណើត និងលេខកូដប្រៃសណីយ។ គេនឹងមិនសរសេរឈ្មោះនិងអាសយដ្ឋានអ្នកនៅលើដបឈាមគំរូនោះទេ។ ចូរសួរវេជ្ជបណ្ឌិតអំពីរបៀបគេប្រើសំរាប់បិទផ្លាកលើដបឈាមគំរូ ពីព្រោះគេអាចប្រើរបៀបខុសគ្នាពីពេទ្យមួយទៅពេទ្យមួយទៀត ឬពីមន្ទីរពេទ្យមួយទៅមន្ទីរពេទ្យមួយទៀត។ គេប្រើរបៀបខុសពីនេះ បើអ្នកទៅធ្វើតេស្តនៅមន្ទីរពេទ្យធំ។ គេច្រើនតែសរសេរឈ្មោះអ្នកនៅលើឈាមគំរូនោះ។

គំរូឈាមត្រូវផ្ញើទៅមន្ទីរពិសោធន៍ដើម្បីធ្វើតេស្ត ហើយលទ្ធផលនឹងត្រូវបញ្ជូនមកវេជ្ជបណ្ឌិតឬគិលានុបដ្ឋាកអ្នកវិញ ក្នុងរវាង 10 ថ្ងៃក្រោយទៀត។

សូមទូរស័ព្ទទៅក្រុមប្រឹក្សាខាងជម្ងឺអេដស៍នៅរដ្ឋញូវសោធវែល (ACON) តាមលេខ (02) 9206 2000 ដើម្បីសុំកូនសៀវភៅពត៌មានដោយឥតគិតថ្លៃ ឈ្មោះ ***HIV Tests and Treatment*** ។

## លទ្ធផល

បើលទ្ធផលជាអវិជ្ជមាន នោះមានន័យថា អ្នកគ្មានមេរោគ HIV ឬចំនួនអង្គបដិបក្ខ HIV នៅមិនទាន់ឡើងគ្រប់ចំនួនអាចឲ្យគេបញ្ជាក់បានទេ។ គេហៅរយៈពេលនេះថា "រយៈពេលចន្លោះ" (windows period) ហើយអាចមានរហូតដល់ 3 ខែ។ អ្នកអាចត្រូវធ្វើតេស្តជាលើកទី 2 ក្នុងពេល 3 ខែបន្ទាប់មក ដើម្បីបញ្ជាក់ពីលទ្ធផលនៃតេស្តដំបូងនោះ។ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកពីរឿងនេះ។ គេហៅ HIV អវិជ្ជមាន (HIV negative) ថាជាអង្គបដិបក្ខអវិជ្ជមាន (antibody negative) និងសេរូមអវិជ្ជមាន (seronegative) ផងដែរ។

ការទទួលទ្ធផលជាអវិជ្ជមានជាឱកាសមួយអាចឲ្យអ្នកធ្វើការគិតគូរឡើងវិញអំពីអំពើឬស្ថានការណ៍ដែលបណ្តាលឲ្យអ្នកសំរេចធ្វើតេស្តរកមេរោគ HIV នេះឡើងវិញ។ *ការទទួលលទ្ធផលជាអវិជ្ជមានមិនអាចការពារខ្លួនអ្នកពីមេរោគ **HIV** បានទេ។* បើអ្នកចង់រួមភេទជាមួយជនណាម្នាក់ ហើយមិនទាន់ដឹងប្រាកដពីប្រវត្តិខាងផ្លូវភេទរបស់គេក្នុងពេលបច្ចុប្បន្ននិងអតីតកាល ឬតើគេមានប្រើគ្រឿងញៀនទេនោះ អ្នកត្រូវប្រើស្រោមលិង្គឬទ្រនាប់យោនីនៅរាល់ពេលដែលអ្នករួមភេទ។ អ្នកត្រូវប្រើរបស់ថ្មីជានិច្ច និងមិនត្រូវប្រើម្ជុលឬប្រដាប់ចាក់ថ្នាំរួមគ្នាទេ។ ត្រូវខំថែរក្សាខ្លួនអ្នក។ សុំឲ្យបុគ្គលិកសុខាភិបាលបង្ហាញអ្នកអំពីរបៀបប្រើស្រោមលិង្គឬទ្រនាប់យោនី បើអ្នកមិនប្រាកដ។

បើលទ្ធផលនៃការធ្វើតេស្តគឺជាវិជ្ជមាន **(positive)** វិញ នោះមានន័យថា អ្នកបានប៉ះពាល់នឹងមេរោគ HIV ហើយបានទទួលឆ្លងមេរោគហើយ។ គេហៅលទ្ធផលនេះថា អង្គបដិបក្ខវិជ្ជមាន (antibody positive) និងសេរូមវិជ្ជមាន (seropositive)។ *លទ្ធផលថាអ្នកមានមេរោគ **HIV** មិនមែនមានន័យថាអ្នកមានជម្ងឺអេដស៍ទេ។*

អ្នកនឹងត្រូវធ្វើតេស្តជាបន្តទៅទៀតដើម្បីបញ្ជាក់អំពីស្ថានភាពនៃប្រព័ន្ធការពារខ្លួនអ្នកដើម្បីឲ្យដឹងអំពីការខូចខាតដែលបណ្តាលមកពីមេរោគនេះ។ នៅក្នុង ដំណាក់ការនេះ ជាការសំខាន់ណាស់ដែលអ្នកត្រូវបង្កើតឲ្យមានទំនាក់ទំនងល្អជាមួយវេជ្ជបណ្ឌិតណាមួយដែលអ្នកទុកចិត្ត ហើយដែលចូលចិត្តស្តាប់ យកចិត្តទុកដាក់នឹងអ្នក ដើម្បីព្យាបាលមេរោគ HIV ។ ស្ត្រីដែលមាន HIV ជាច្រើនរកឃើញថា ការរកអ្នកជួយព្យាបាលជាបន្ថែមម្នាក់ទៀត អាចជាជំនួយឲ្យគេរក្សាសុខភាពនិងសុខុមាលភាពរបស់គេ។

ដើម្បីទទួលពត៌មានបន្ថែមទៀតអំពីបញ្ហាទាំងនេះ
សូមអានប័ណ្ណពត៌មានស្តីអំពីការព្យាបាល
និងអ្នកដែលគេទើបតែរកឃើញថាមានមេរោគ
ដែលមានផ្សាយនៅក្នុងលេខបន្តបន្ទាប់។

## បើអ្នកមានផ្ទៃពោះឬចង់មានផ្ទៃពោះ

បើអ្នកកំពុងមានផ្ទៃពោះ អ្នកតែងតែទទួលការធ្វើតេស្តតាមទម្លាប់ធម្មតានៅមន្ទីរពិគ្រោះមុនពេលឆ្លងទន្លេ ឬគ្រូពេទ្យអ្នក ដើម្បីធ្វើការពិនិត្យមួយចំនួន ដូចជាជម្ងឺស្វូចជាដើម។ល។ ការធ្វើតេស្តរកមើលមេរោគ HIV មិនដូចតេស្តទាំងអស់នោះទេ ទោះបីជាគ្រូពេទ្យខ្លះបានធ្វើតេស្តដោយគ្មានសួរយល់ព្រមពីស្ត្រីទាំងនោះក៏ដោយ។ បើអ្នកមិនប្រាកដ សូមសួរគ្រូពេទ្យ ថាតើគេកំពុងធ្វើតេស្តពីរោគអ្វី? ឬ ហើយមានន័យដូចម្តេច?។ បើអ្នកចង់មានផ្ទៃពោះ អ្នកអាចសុំឲ្យគេធ្វើតេស្តមើលមេរោគ HIV សិន បើអ្នកគិតថា អ្នកប្រហែលជាមានគ្រោះថ្នាក់។

ចំពោះពត៌មានបន្ថែមអំពីការមានផ្ទៃពោះ
សម្រាប់ស្ត្រីដែលមានមេរោគ **HIV**
សូមអានប័ណ្ណពត៌មានស្តីអំពី
ការមានផ្ទៃពោះ ក្នុងលេខបន្តបន្ទាប់។

## តើជនណាទៅដែលអាចមានច្បាប់តម្រូវឲ្យអ្នកធ្វើតេស្ត **HIV** បាន?

ច្បាប់នៅប្រទេសអូស្ត្រាលីតម្រូវឲ្យជនដែលចង់រស់នៅជាអចិន្ត្រៃយ៍ ត្រូវធ្វើតេស្ត HIV ហើយផ្តល់លទ្ធផលដល់ក្រសួងអន្តោប្រវេសន៍។ នេះគឺជាសេចក្តីតម្រូវតាមច្បាប់។

ក្រុមហ៊ុនធានារ៉ាប់រងក៏អាចមានសិទ្ធិតម្រូវឲ្យអ្នកធ្វើតេស្ត និងផ្តល់លទ្ធផលឲ្យគេ។ គេអាចតម្រូវឲ្យអ្នកបង្ហាញថា អ្នកគ្មានមេរោគ HIV មុនពេលគេព្រមធានារ៉ាប់រងអ្នក។

នៅពេលខ្លះ អ្នកវិជ្ជាជីវៈខ្លះដូចជាពេទ្យធ្មេញ ពេទ្យវះកាត់ វេជ្ជបណ្ឌិត អាចសួរ តើអ្នកធ្លាប់បានធ្វើតេស្តពីមុនឬទេ ឬគេសុំឲ្យអ្នកធ្វើតេស្តហើយផ្តល់លទ្ធផលឲ្យគេ។ ច្បាប់មិនតម្រូវឲ្យអ្នកគោរពតាមបញ្ជានោះទេ អ្នកអាចបដិសេធបាន។ តែបើគេបដិសេធមិនព្រមព្យាបាលរោគ ឬធ្មេញ ដោយសារតែគេដឹងថាអ្នកមានមេរោគ HIV នោះ ចាត់ទុកជាការរើសអើង ហើយជាអំពើផ្ទុយនឹងច្បាប់។

បើគេមិនព្រមព្យាបាលអ្នកដោយសារតែអ្នកមិនព្រមធ្វើតេស្ត HIV អ្នកអាចទាក់ទងគណកម្មការសិទ្ធិមនុស្សនិងភ័ព្វសំណាងស្មើគ្នា (Human Rights and Equal Opportunities Commission) ឬក្រុមប្រឹក្សាប្រឆាំងអំពើរើសអើងពូជសាសន៍រដ្ឋញូវសោធវែល (NSW Anti-Discrimination Board) ដើម្បីសុំពត៌មាននិងយោបល់តាមច្បាប់ តាមស្ថានភាពរបស់អ្នក។

លេខទូរស័ព្ទ:

**Human Rights and Equal Opportunities Commission**

Ph (02) 9284 9600, ឬ

1 800 021 199 (ឥតបង់ថ្លៃ)

TTY: 1 800 620 241

**NSW Anti-Discrimination Board**

Ph (02) 9318 5400

1800 670 812 (ឥតបង់ថ្លៃ)

**លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ពក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលៈទេសៈ។ លោក-អ្នក ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង"សៀវភៅទូរស័ព្ទ" (Telephone Directory)។**

01/01